ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

តុលាការកំពូល

១៣១១

សភាទីផ្នែករដ្ឋប្បវេណី

សំណុំរឿងរដ្ឋប្បវេណី

លេខ : ៣៦៣

ចុះថ្ងៃទី១៦ ខែវិច្ឆិកាឆ្នាំ១៩៩៧

<u>សាលដីកា</u>

លេខ: ១៥៦

ចុះថ្ងៃទី១៦ខែកក្កដាឆ្នាំ១៩៩៨

---

តាងនាមប្រជារាស្ត្រខ្មែរ

តុលាការកំពូល

បាន បើកសវនាការជំនុំជំរះជាសាធារណៈនៅថ្ងៃទី ១៦ ខែ កក្កដា ឆ្នាំ ១៩៩៨ ដោយមានសមាសភាពដូចតទៅ : -

១- ឯកឧត្តម ឌិត មុន្ទី ជាប្រធាន

២- លោក ខឹប៉ុន ស៊ិន ជាចៅក្រមរាយការណ៍

៣- លោក ទៀល ជួន ជាចៅក្រម

៤- លោក ស៊ិន ឌឹម ជាចៅក្រម

៥- លោក ជីវ កេង ជាចៅក្រម

ក្រឡាបញ្ជី

លោក ស៊ុង ម៉ៅ

តំណាងអយ្យការ

លោក សាយ សារី ជាព្រះរាជអាជ្ញា

ដើម្បីជំនុំជំរះលើបណ្តឹងសាទុក្ខពីសាលដីកាលេខ ៥៤៧ ចុះថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ១៩៩៧ នៃសំណុំរឿងរដ្ឋប្បវេណីលេខ ៧៥៧ ចុះថ្ងៃទី ២៦ ខែ ធ្នូ ឆ្នាំ ១៩៩៦ របស់សាលាឧទ្ធរណ៍ ។

រវាងម្ចាស់បណ្តឹងសាទុក្ខឈ្មោះ លី អេង ភេទ ស្រី អាយុ ៤៥ ឆ្នាំ ជាតិ ខ្មែរ របរ រកស៊ី លក់ដូរ ទីលំនៅពុ ភូមិទី ៨ ឃុំកំពង់ចាម ស្រុកកំពង់ចាម ខេត្តកំពង់ចាម ។ ឪពុកឈ្មោះ ម៉េង លី "ស" ម្តាយឈ្មោះ ផេង ហាក់ "រ" ប្តីឈ្មោះ ហាក់ អាន មានកូន២នាក់ ។ មានមេធាវីឈ្មោះ វិណ្ណ ផលលា ។

និងចុងចម្លើយបណ្តឹងសាទុក្ខឈ្មោះ ម៉ក់ ផេង ភេទស្រី អាយុ ៦៨ ឆ្នាំ ជាតិខ្មែរ របរ រកស៊ីនៅផ្ទះ ទីលំនៅពុ ភូមិទី ៨ ឃុំ - ស្រុក ខេត្ត កំពង់ចាម ។ ឪពុកឈ្មោះម៉ក់ "ស" ម្តាយឈ្មោះ ទេឡន "ស" ប្តីឈ្មោះ ប៊ី "ស" មានកូន៦នាក់ ។

<u>កម្មវត្ថុ</u> : ប្តឹងសុំសិទ្ធិគ្រប់គ្រងដំបូលខ្ទាំង និង សុំសិទ្ធិគ្រប់គ្រងជញ្ជាំងខាងក្រោយ ។

បាន ឃើញបណ្តឹងសាទុក្ខលេខ ៣៤៦ ចុះថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ១៩៩៧ របស់ឈ្មោះ លី អេង ប្តឹងមិនសុខចិត្តពីសាលដីការដ្ឋប្បវេណីលេខ ៥៤៧ ចុះថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ១៩៩៧ របស់សាលាឧទ្ធរណ៍ លើសេចក្តីបំរេបទាំងមូលធ្វើឡើងក្នុងកំណត់ច្បាប់ ។

បាន ឃើញសំណុំរឿងរដ្ឋប្បវេណីលេខ ៣៦៣ ចុះថ្ងៃទី១៦ ខែ វិច្ឆិកា ឆ្នាំ ១៩៩៧ របស់ តុលាការកំពូល ។

---

សាលដីការដ្ឋប្បវេណីលេខ ១៥៦ ចុះថ្ងៃទី ១៦ ខែ កក្កដា ឆ្នាំ ១៩៩៧ របស់តុលាការកំពូល ។

តាមពាក្យបណ្ដឹងចុះថ្ងៃទី ១៥.៣-៩៦ អ្នកស្រី លី អេង បានប្ដឹងសុំរក្សាសិទ្ធិជញ្ជាំងផ្ទះចាស់នៅភាពដើមដីដែលសុំរក្សាសិទ្ធិដំបូលផ្ទះ និង សុំជួសជុលបំពង់ទឹកដែលបែកពីឈ្មោះ ម៉ក់ ផេង ដោយសំអាងហេតុថាអ្នកស្រី ម៉ក់ ផេង បានរំលោភសិទ្ធិមកលើខ្លួនចង់ចោះជញ្ជាំងដែលនៅជាប់គ្នាដាក់ទ្វារដែក ។ ម៉្យាងទៀតកន្លែងដែលអ្នកស្រី ម៉ក់ ផេង ចង់ចោះនោះជាកន្លែងខ្លួនងូតទឹក កាលពីមុនកន្លែងនោះជាទ្វារចាស់មែន តែពេលនោះផ្ទះខ្លួន និង ផ្ទះអ្នកស្រី ម៉ក់ ផេង ជាម្ចាស់តែមួយ ប៉ុន្តែផ្ទះនេះពេលខ្លួនចូលនៅ ឃើញជញ្ជាំងនេះបិទជិតស្រាប់ ។ ហើយអ្នកស្រី ម៉ក់ ផេង បានហាមឃាត់ខ្លួន មិនអោយឡើងលើដំបូលផ្ទះរបស់ខ្លួននិង ហាមមិនអោយខ្លួនធ្វើការជួសជុលបំពង់ទឹកដែលបែកហូរចូលមកក្នុងផ្ទះរបស់ខ្លួន ហើយថែមទាំងបិទរន្ធខ្យល់ផ្នែកតាមជញ្ជាំងទៀតផង ។

បានឃើញសាលក្រមរដ្ឋប្បវេណីលេខ ១៣០ "ក" ចុះថ្ងៃទី ២៨ ខែ កក្កដា ឆ្នាំ១៩៩៦ របស់តុលាការខេត្តកំពង់ចាម ដែលមានខ្លឹមសារនៃសេចក្ដីសំរេចដូចតទៅ :-

១ - ទទួលពាក្យបណ្ដឹងរបស់ដើមចោទឈ្មោះ លី អេង ចុះថ្ងៃទី ១៥ ខែមិនា ឆ្នាំ ១៩៩៦ ទុកជាត្រឹមត្រូវតាមទំរង់ច្បាប់និង គតិច្បាប់ខ្លះៗ ។

២ - ទទួលពាក្យបណ្ដឹងសាត្រឡប់របស់ចុងចម្លើយនាពេលសវនាការដែលសុំបើកទ្វារចេញចូលប្រកឿងថែមក្រោយផ្ទះទុកជាត្រឹមត្រូវតាមទំរង់ច្បាប់ និង គតិច្បាប់ ។

៣ - ទទួលស្លាកលិខិតកាន់កាប់ផ្ទះរបស់ដើមចោទលេខ ០០១០៣៣ រ ក ច ចុះថ្ងៃទី ១២-១០-៩១ ទុកជាត្រឹមត្រូវតាមទំរង់ច្បាប់និង គតិច្បាប់ "អនុក្រិត្យលេខ ២៥"

៤ - ទទួលស្លាកលិខិតកាន់កាប់ផ្ទះរបស់ចុងចម្លើយលេខ៣៦០៨ ក ច ចុះថ្ងៃទី២៥ខែឧសភា ឆ្នាំ ១៩៩២សំរាប់ជាន់ទី១ និង សេចក្ដីសំរេចលេខ ០០០៤ ក ច ចុះថ្ងៃទី ២៦.១១.៩០ ទុកជាត្រឹមត្រូវតាមទំរង់ច្បាប់ និង គតិច្បាប់ ។ អនុក្រិត្យលេខ ២៥"

៥ - រក្សាសិទ្ធិអោយដើមចោទឈ្មោះ លី អេង កាន់កាប់ទាំងដំបូលថ្មីដែលមានក្នុងសេចក្ដីសំរេចរបស់ខ្លួនជាកម្មសិទ្ធិ ហើយធ្វើជណ្ដើរឡើងតាមផ្លូវផ្ទះរបស់ខ្លួន ។ ការទាមទារលើសពីនេះលើកចោល ។ មាត្រា ១៩ នៃច្បាប់ភូមិបាលស្ដីពីកម្មសិទ្ធិ"

៦ - រក្សាសិទ្ធិអោយចុងចម្លើយឈ្មោះ ម៉ក់ ផេង ចេញចូលតាមជឿងថែមខាងត្បូងផ្ទះដោយអោយឈ្មោះ លី អេង រើបង្គន់របស់ខ្លួនចេញចាប់ពីពេលដែលសាលក្រមនេះចូលជាស្ថាពរ ។ ការទាមទារលើសពីនេះលើកចោល ។ "ផ្នែកទី៣ស្ដីពីកម្មសិទ្ធិរួមឬ សហកម្មសិទ្ធិនៃច្បាប់ភូមិបាល"

៧ - សោហ៊ុយប្រាក់ប្រដាប់ក្ដី ពន្ធចុះបញ្ជីក្ដី ពន្ធហ្វឹង ១៨០០រៀលរង្វាន់ក្រឡាបញ្ជីការពីរប ប្រាក់ ២០០រៀល រង្វាន់អ្នកប្រគល់ដីកាកោះ ៥០០០រៀល សរុប ៧០០០រៀល ប្រាក់នេះបានកាត់យកពីប្រាក់៧០០០រៀលដែលដើមចោទបានបង់រួចពេលសាលក្រមចូលស្ថាពរបង្គាប់អោយចុងចម្លើយបង់សងទៅដើមចោទវិញ ។

៨ - សាលក្រមនេះប្រកាសជាសាធារណៈចំពោះមុខដើមចោទនិងចំពោះមុខចុងចម្លើយបើភាគីណាមិនសុខចិត្តភាគីនោះមានសិទ្ធិប្ដឹងឧទ្ធរណ៍តាមច្បាប់កំណត់ ។

បាន ឃើញបណ្ដឹងឧទ្ធរណ៍ចុះថ្ងៃទី០២ខែ កញ្ញា ឆ្នាំ ១៩៩៦របស់ឈ្មោះ ម៉ក់ ផេង ប្ដឹងមិនសុខ

---

ចិត្ត និងសាលក្រមរដ្ឋប្បវេណីលេខ ១៣០ "ក" ចុះថ្ងៃទី២៨ ខែ កក្កដា ឆ្នាំ ១៩៩៦ របស់តុលាការខេត្តកំពង់ចាម លើចំណុចនៃសាលក្រមទាំងមូល ។

បានឃើញសាលដីការដ្ឋប្បវេណីលេខ ៥២៧ ចុះថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ១៩៩៧ របស់សាលាឧទ្ធរណ៍ ដែលមានខ្លឹមសារនៃសេចក្ដីដូចតទៅ :-

១- ទទួលពាក្យបណ្ដឹងឧទ្ធរណ៍ចុះថ្ងៃទី០២-៨-១៩៩៦ របស់ឈ្មោះ ម៉ក់ ផេង ទុកជាត្រឹមត្រូវតាមទំរង់ និង គតិច្បាប់ ។

២- បដិសេធសាលក្រមរដ្ឋប្បវេណីលេខ ១៣០ "ក" ចុះថ្ងៃទី ២៨.៧.១៩៩៦ របស់តុលាការខេត្តកំពង់ចាមចោលជាភាពរបស់ ។

៣- ក : ប្រគល់ផែទំរាល់ទំនាស់នៃផ្ទះលេខ៦២៨អ៊ីអង ដែលស្ថិតនៅក្នុងក្រុមផ្ទះ ភូមិ៨ សង្កាត់កំពង់ចាម ទីរួមខេត្តកំពង់ចាមទៅអោយឈ្មោះ ម៉ក់ ផេង គ្រប់គ្រង និង កាន់កាប់ជាកម្មសិទ្ធិតទៅ ។

ខ : បង្គាប់អោយឈ្មោះ ម៉ក់ ផេង ធ្វើការជួសជុល និង ថែរក្សាផែទំរាល់ទំនាស់នេះកុំអោយជ្រាបទឹក ឬ ធ្លុះធ្លាយទៅលើផ្ទះខាងក្រោម ។

គ : អនុញ្ញាតអោយឈ្មោះ ម៉ក់ ផេង បើកទ្វារចេញចូលតាមច្រកជណ្ដើរខាងក្រោយផ្ទះ ។

ឃ : បង្គាប់អោយឈ្មោះ លី អេង ដោះរើបង្គន់ចេញពីផ្លូវជណ្ដើរខាងក្រោមនេះនៅពេលដែលសាលដីកាចូលជាស្ថាពរ ។

៤- សំរេចការសងប្រាក់ប្រដាប់ក្ដីនៅជាន់សាលាឧទ្ធរណ៍ចំនួន ១៣.០០០រៀលដែលដើមបណ្ដឹងឧទ្ធរណ៍បានបង់រួចហើយ គឺពន្ធចុះបញ្ជីក្ដី និង ពន្ធបណ្ដឹង២៥៥០រៀល រង្វាន់ក្រឡាបញ្ជីកាត់ពីប្រាក់៤៥០៥ចំណាយលើការប្រគល់ដីកាកោះ ៥០០០រៀល ។ កាលបើសាលដីកានេះមានអានុភាពអនុវត្តហើយបង្គាប់អោយឈ្មោះ លី អេង សងប្រាក់ចំនួន ១៣.០០០រៀលនេះទៅឈ្មោះ ម៉ក់ ផេង វិញ ។

៥- សាលដីកានេះជំនុំជំរះ និង ប្រកាសជាសាធារណៈចំពោះមុខគូក្ដី សំរេចបើកផ្លូវប្ដឹងសាទុក្ខក្នុងកំណត់ច្បាប់ ។

បានឃើញបណ្ដឹងសាទុក្ខលេខ ៣៤៦ ចុះថ្ងៃទី ១៥ ខែកញ្ញា ឆ្នាំ ១៩៩៧ របស់ឈ្មោះ លី អេង ប្ដឹងមិនសុខចិត្តពីសាលដីការដ្ឋប្បវេណីលេខ ៥២៧ ចុះថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ១៩៩៧ របស់សាលាឧទ្ធរណ៍ លើសេចក្ដីសំរេចទាំងមូលធ្វើឡើងក្នុងកំណត់ច្បាប់ ។

បានឃើញសារណាចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៧ របស់ឈ្មោះ លី អេង ។

បានឃើញសារណាតបចុះថ្ងៃទី ១៤ ខែ មិនា ឆ្នាំ ១៩៩៨ របស់ឈ្មោះ ម៉ក់ ផេង ។

បានស្ដាប់ចៅក្រមរបាយការណ៍ របស់ចៅក្រមរបាយការណ៍

បានស្ដាប់សេចក្ដីសន្និដ្ឋាន របស់តំណាងអយ្យការថា : សាលដីការបស់សាលាឧទ្ធរណ៍បានសំរេចត្រឹមត្រូវ និង គតិច្បាប់ ។ សូមក្រុមប្រឹក្សាជំនុំជំរះសំរេចតាមច្បាប់ ។

បានស្ដាប់ចម្លើយរបស់ឈ្មោះ លី អេង ជាដើមចោទ និង ជាម្ចាស់បណ្ដឹងសាទុក្ខនៅពេលជំនុំជំរះបានឆ្លើយបញ្ជាក់ថា :

---

សាលដីការដ្ឋប្បវេណីលេខ ១៥៦ ចុះថ្ងៃទី ១៦ ខែ កក្កដា ឆ្នាំ ១៩៩៨របស់តុលាការកំពូល ។

ខ្ញុំប្តឹងដំបូងខ្ញុំកាន់កាប់ដីទំនាស់ ជាកម្មសិទ្ធិតាំងពីឆ្នាំ ១៩៨៧ មកម្លេះអស់រយៈពេល១១ឆ្នាំហើយផ្ទះនេះខ្ញុំទិញពីវណ្ណា មិនពាក់ព័ន្ធនិង ម៉ក់ ផេង ទេ គាត់ទិញក្រោយគាត់ទាមទារខ្ញុំទិញមានចុងចម្លើយ និង រដ្ឋអំណាចដឹងឮនិងទទួលស្គាល់ផងកន្លងមកខ្ញុំមិនដឹងដោយខ្ញុំមិនបានឡើងមើលខាងលើក្រោយមកដោយខ្ញុំចង់ជួសជុលចុងចម្លើយមិនអោយជួសជុលទេ ។ ឯជញ្ជាំងជណ្ដើរថែមគេបិទពីឆ្នាំ ១៩៨៩ មកឯជណ្ដើរថែមមួយគេមិនបិទទេឯជណ្ដើរថែមជាប់ផ្ទះនេះគេបិទយូរហើយ ក្រោយមកគាត់ចង់ចោះយកខ្យល់អាកាសតែកន្លែងនោះល្មមទឹកស្អុយទេ ទើបគាត់ចង់បើកជញ្ជាំងខ្ញុំ គ្រួសារពីរបីទៀតក៏គេមិនបើកអោយដែរ ពេលទិញគេបិទរួចទៅហើយគាត់ហាមឃាត់មិនអោយខ្ញុំប៉ះជញ្ជាំងទេ ដែលជញ្ជាំងនោះធ្វើយូរហើយ ។ ខ្ញុំសូមអោយចុងចម្លើយស្បថជាមួយខ្ញុំនៅតុលាការបើខ្ញុំនិយាយខុស ។

បានឃើញចម្លើយរបស់ឈ្មោះ ម៉ក់ ផេង ជាចុងចម្លើយ និង ជាចុងបណ្ដឹងសាទុក្ខនៅពេលជំនុំជំរះបានឆ្លើយបញ្ជាក់ថា : ផ្ទះនេះគេចែកដាច់ស្រេចរួចហើយ ជញ្ជាំងខ្ញុំមិននៅចំជណ្ដើរថែមគេទេតែដើមចោទមកកាន់កាប់ ពីមុនខ្ញុំខ្វះលុយក្រោយមកខ្ញុំមានលុយចង់ធ្វើទ្វារដែកបិទបើកដើរទៅជណ្ដើរថែមដើមចោទមិនព្រមព្រោះខ្លាចប៉ះពាល់ទឹករបស់គេ ។ ដោយហេតុដើមចោទបិទជញ្ជាំងពេលភ្លៀងមកទឹកហូរចូលផ្ទះខ្ញុំ ។

មេធាវីរបស់ដើមចោទបានធ្វើសេចក្ដីសន្និដ្ឋានថា : កូនក្ដីខ្ញុំរស់នៅលើផ្ទះល្វែងតាំងពីឆ្នាំ ១៩៨៧មក ការរស់នៅមានលិខិតស្នាមមុខនិងស្នាមមេដៃរបស់ចុងចម្លើយនិងរដ្ឋអំណាចផង ពីបញ្ហាដីទំនាស់ជាកម្មសិទ្ធិរបស់ លី អេង ។ ជញ្ជាំង លី អេង គ្រប់គ្រងបានជាង១០ឆ្នាំហើយការរស់នៅរបស់ដើមចោទមិនមានទំនាស់អ្វី និង អ្នកជិតខាងទេការទិញផ្ទះរបស់ចុងចម្លើយបន្តមកនោះនៅជាប់ផ្ទះ លី អេង មិនមានការដឹងឮពីដើមចោទនិង រដ្ឋអំណាចទេមិនមានការបញ្ជាក់ពីព្រំប្រទល់ទេ ជញ្ជាំងខាងក្រោយរបស់ លី អេង បើចុងចម្លើយចង់បើកជញ្ជាំងគាត់មិនអាចចេញទៅក្រៅបានដែរ ។ សំណូមពរមិនព្រមប្រគល់ជញ្ជាំងក្រោយអោយដើមចោទទេ ។ មិនព្រមប្រគល់ដីទំនាស់ខាងលើអោយចុងចម្លើយ និង ទាមទារជំងឺចិត្ត ៣០០០ដុល្លារអាមេរិច ។

ក្រោយពីបានស្ដាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

ក្រោយពីបានស្ដាប់សេចក្ដីសន្និដ្ឋានរបស់តំណាងអយ្យការ

ក្រោយពីបានស្ដាប់ចម្លើយដោះសាររបស់គូភាគី និង សេចក្ដីសន្និដ្ឋានរបស់មេធាវី

ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ ហើយ

## តុ លា កា រ កំ ពូ ល

- យល់ឃើញថា : បណ្ដឹងសាទុក្ខលេខ ៣៤៦ ចុះថ្ងៃទី១៥.៩.៩៧ របស់អ្នកស្រី លី អេង ធ្វើឡើងក្នុងកំណត់ច្បាប់តុលាការកំពូលអាចលើកឡើងនេះមកជំនុំជំរះបានតាមមាត្រា៦៤ នៃច្បាប់ស្ដីពីការចាត់តាំង និង សកម្មភាពរបស់សាលាជំរះក្ដី ។

- យល់ឃើញថា : ការដែលសាលាឧទ្ធរណ៍សំរេចប្រគល់ដីទំនាស់នៃផ្ទះទំនាស់អោយទៅអ្នកស្រី ម៉ក់ ផេង នោះជាការភាន់ច្រឡំពីព្រោះថាដីទំនាស់នេះជាឧបសម្ព័ន្ធនៃផ្ទះខាងក្រោមដែលជារបស់អ្នកស្រី លី .អេង ហើយដែលអ្នកស្រី រូបនេះបានគ្រប់គ្រង និងកាន់កាប់កន្លងមកម៉្យាងទៀត

សាលដីការដ្ឋប្បវេណីលេខ ១៥៦ ចុះថ្ងៃទី ១៦ ខែ កក្កដា ឆ្នាំ ១៩៩៨ របស់តុលាការកំពូល ។

តាមសេចក្ដីសំរេចលេខ០០៧០ ក ស រ ក ច ចុះថ្ងៃទី ១២.១០.៩១ គណៈកម្មាធិការខេត្តកំពង់ចាម បានសំរេចប្រគល់ផ្ទះលេខ ៦២៩ជាន់ក្រោមបូកនិងជាន់ទី១ អោយអ្នកស្រី លី អេង គ្រប់គ្រង ។

- យល់ឃើញថា : តុលាការថ្នាក់ក្រោមពុំបានធ្វើការអង្កេតអោយបានច្បាស់លាស់អំពីជញ្ជាំង ខាងក្រោយនៃផ្ទះទំនាស់នេះឡើយ ។

- យល់ឃើញថា : អ្នកស្រី លី អេង បានទទួលដីកាកោះអោយមកចូលរួមសវនាការនេះតាំងពីថ្ងៃទី០៩.៧.៩៨ ហើយអ្នកស្រី ទើបតែពឹងមេធាវីអោយការពាររឿងរបស់ខ្លួនតាមសវនាការនេះ តែម្ដង ដូច្នេះការ ដែល មេធាវីអ្នកស្រី សុំលើកពេលសវនាការនេះទៅពេលក្រោយដើម្បីសិក្សា សំណុំរឿងនេះតុលាការកំពូលពុំអាចអោយបានទេ ហើយការទាមទារដងចិត្តរបស់លោក មេធាវី អ្នកស្រី លី អេង តុលាការកំពូលពុំមានសមត្ថកិច្ចពិចារណាទេឡើយ ។

- យល់ឃើញថា : សាលដីការដ្ឋប្បវេណីលេខ ៥៤៧ ចុះថ្ងៃទី ១៥.៩.៩៧ របស់ សាលា ឧទ្ធរណ៍ ដែលបានសំរេចសេចក្ដីមកនេះ មានការខុសឆ្គងទាំងទំរង់ ទាំង គតិច្បាប់ ។

ហេតុដូច្នេះ

វិនិច្ឆ័យសេចក្ដី ចំពោះមុខក្ដី

១- ទទួលបណ្ដឹងសាទុក្ខលេខ ៣៤៦ ចុះថ្ងៃទី ១៥.៩.៩៧ របស់អ្នកស្រី លី អេង ទុក ជាត្រឹមត្រូវតាមទំរង់ និង គតិច្បាប់ ។

២- ទុកជាមោឃៈសាលដីការដ្ឋប្បវេណីលេខ ៥៤៧ ចុះថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ១៩៩៧ របស់សាលាឧទ្ធរណ៍ទាំងមូល ។

៣- បញ្ជូនសំណុំរឿងរដ្ឋប្បវេណីលេខ ៣៦៣ ចុះថ្ងៃទី ១១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៧ របស់តុលាការកំពូល ទៅសាលាឧទ្ធរណ៍ ដើម្បីជំនុំជំរះជាថ្មីឡើងវិញ ។

៤- រឹបអូសប្រាក់ប្រដាប់ក្ដីដែលអ្នកស្រី លី អេង បានបង់រួចហើយចំនួន១៩.០០០រៀលគឺ

- ពន្ធចុះបញ្ជីក្ដី និង ពន្ធហ៊ឹងចំនួន ៤០០០រៀល ប៉ុន្តែប្រាក់នេះត្រូវកាត់ចំនួន៨០០រៀល សំរាប់ជារង្វាន់ក្រឡាបញ្ជី ការពិបប្រាក់ .

- ចំណាយលើកិច្ចប្រគល់ដីកាកោះចំនួន១៥.០០០រៀល សរុប ១៩.០០០រៀលហើយ ត្រូវអោយអ្នកស្រី ម៉ក់ ផេង សងប្រាក់ចំនួន ១៩.០០០រៀលទៅអ្នកស្រី លី អេង វិញ ។

៥- សាលដីការនេះប្រកាសតាមសវនាការជាសាធារណៈ នៅថ្ងៃទី១៦ ខែ កក្កដា ឆ្នាំ ១៩៩៨ ។